# ពិធីសែនក្រុងពាលីក្នុងតន្ត្រីខ្មែរ

ក្នុងពិធីសាសនា នៅប្រទេសកម្ពុជា ដូចជាពិធីបញ្ចុះសីមា ពិធីឡើងផ្ទះ ការសាងសង់អគារថ្មី ការរៀបចំព្រឹត្តិការណ៍សិល្បៈ ឬពិធីរៀបមង្គលការជាដើម គេតែងប្រារព្ធធ្វើ «ពិធីប្រុងពលី ឬក្រុងពាលី»។[១] គេធ្វើពិធីនេះឡើង ដើម្បីសុំម្ចាស់ទឹកម្ចាស់ដី ដើម្បីឱ្យគម្រោង ព្រឹត្តិការណ៍ និងកម្មវិធីដែលរៀបចំ ប្រព្រឹត្តទៅដោយសុខសប្បាយ ជោគជ័យ មិនមានឧបសគ្គភ័យន្តរាយណាមួយកើតឡើងឬរារាំងរំខាន។

កាលណានិយាយពាក្យ «ប្រុងពលី ឬក្រុងពាលី» គឺគេសំដៅដល់ពិធីសែនព្រេនបួងសួងដើម្បីសុំសេចក្ដីសុខសប្បាយពីម្ចាស់ទឹកម្ចាស់ដី។ ក្រុងពាលី ជាឈ្មោះនៃស្ដេចស្វាជាម្ចាស់ទឹកម្ចាស់ដីដំបូងបង្អស់ ដែលអ្នកធ្វើពិធីនានានៅលើផែនដី ត្រូវសុំការអនុញ្ញាតជាមុន។ ពាក្យថា «ក្រុង» ក្នុងទីនេះ ពុំមានន័យថា «បុរី រដ្ឋ ឬទីប្រជុំជន» ដូចធម្មតានោះទេ តែមានន័យថា «ស្ដេច» ដូចជាពាក្យថា «ក្រុងពពណ៌ ក្រុងអសុរ» ជាដើម។

«ពលី» គឺពលីនាងគង្ហីង ដែលជានិមិត្តរូបនៃដី។ អ្នកដែលគេឧទ្ទិសទៅនោះហៅថា «ក្រុងពាលី»។ តាមន័យទាំងពីរនេះ ឃើញថា «ប្រុងពលី និងក្រុងពាលី» ជាពាក្យដែលមានទំនាក់ទំនងគ្នា ក្នុងពិធីបន់ស្រន់សុំការអនុញ្ញាតធ្វើពិធីផ្សេងៗដូចបានរៀបរាប់ខាងលើ ពីម្ចាស់ទឹកម្ចាស់ដី គឺប្រុងពលី សំដៅដល់ពិធីការ ហើយក្រុងពាលី សំដៅដល់អ្នកទទួលផលពីពិធីការនោះ។ ជារួម កាលណាបើយើងនិយាយពីពិធី គប្បីហៅថា «ពិធីប្រុងពលី» តែបើចង់ប្រើពាក្យថា ក្រុងពាលី គប្បីប្រើថា «ពិធីសែនក្រុងពាលី» ព្រោះពាក្យថា «សែន» ក៏សំដៅដល់សកម្មភាពបូជា ថ្វាយ លះបង់ ដូចនឹងពាក្យថា «ពលី» ជាភាសាបាលីដែរ។ ដោយអាស្រ័យលើជំនឿយ៉ាងខ្លាំងទៅលើស្ដេចក្រុងពាលីនេះហើយ ទើបប្រជាជនខ្មែរគ្រប់ទឹកន្ទេងរៀបចំពិធីនេះពុំដែលខកខាន។[២]

ដោយឡែក នៅក្នុងរឿង រាមកេរ្តិ៍ ខ្មែរ ពាលី ជាស្ដេចស្វាពណ៌បៃតង គ្រងរាជនៅខាស់ខិនបុរី ជាព្រះរាជបុត្ររបស់ព្រះនាងកញ្ចនានិងព្រះឥន្ទ្រ ទើបមានស្បែកនិងមុខ

[១] ពិធីក្រុងពាលី ក្នុង Wikipedia

[២] ពិធីក្រុងពាលី ក្នុង Wikipedia

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ពណ៌បៃតង។ សាច់រឿងក៏បានបង្ហាញថា ព្រះឥសូរ បានប្តូរឈ្មោះស្តេចស្វានេះទៅជា «ពាលីធិរាជ្យ» ដែលមានន័យថា «អ្នកមានកម្លាំងឫទ្ធីខ្លាំងក្លា» ព្រមទាំងបានឱ្យត្រីសូលមួយទៅពាលីផង។[៣]

ពាលី គឺជាស្តេចស្វាមួយដែលមានអំណាចសម្បើមខ្លាំងក្លា។ ដោយមានការប្រទានពរពីព្រះវិស្ណុ ពាលីមានកម្លាំងគ្មានដែនកំណត់ ហើយគ្មាននរណាអាចផ្តួលផ្តួលបាន។ តាមការបកស្រាយរបស់ Narayan (១៩៧២) ពីបុរាណកាលមក ទេវតានិងយក្សបានព្យាយាមកូរសមុទ្រដើម្បីយកទឹកអម្រឹត ដោយប្រើភ្នំព្រះសុមេរុជាទម្រ ប៉ុន្តែគេមិនអាចបង្វិលត្បាល់ដែលជាជន្ទល់នោះបាន។ តាមការស្នើសុំពីទេវតា ពាលីបានច្រានអ្នកទាំងអស់ចេញ ហើយបង្វិលត្បាល់នោះរហូតទទួលបានទឹកអម្រឹត ដែលទេវតាបានសោយនិងរួចផុតពីសេចក្តីស្លាប់។[៤]

ការសិក្សាតន្ត្រីប្រពៃណីបុរាណខ្មែរ ធ្វើឡើងនៅក្នុងវត្តអារាម សាលារៀន ផ្ទះរបស់គ្រូ ឬគេត្រូវសាងសង់រោងរៀននៅទីណាមួយ។ មុននឹងសង់រោង គេត្រូវធ្វើពិធីសុំទឹកសុំដីនិងសែនក្រុងពាលី។ ចំពោះរឿងរ៉ាវក្រុងពាលីនេះ មានច្រើនខុសៗគ្នាទៅតាមការនិយាយតៗគ្នារបស់អ្នកស្រុក។ ខាងក្រោមនេះ ជារឿងពាក់ព័ន្ធនឹងពិធីសែនក្រុងពាលី ដូចតទៅ៖

ប្រភពមួយតំណាលថា កាលពីព្រេងនាយ ថាកាលដែលកទឹកកដីដំបូងនោះ មាននាគពីរជាបងប្អូននឹងគ្នា បងឈ្មោះក្រុងពាលី ប្អូនឈ្មោះព្រះភូមិ ដែលជាអ្នកមានឥទ្ធិឫទ្ធិបានបង្កើតឱ្យមានមនុស្ស សត្វ ព្រឹក្សាលតាវល្លិ៍គ្រប់បែបយ៉ាង នៅលើផែនដីថ្មីនោះ ហើយក៏តាំងខ្លួនជាម្ចាស់ទឹកម្ចាស់ដីនោះទៅ។ ក្រោយមក មានព្រះពុទ្ធមួយព្រះអង្គ ព្រះនាមព្រះពុទ្ធបទុមុត្តរៈ ទ្រង់បានត្រាស់ដឹង ហើយក៏ចង់បាននគរនោះមកកាន់សាសនាព្រះអង្គក៏ប្រើនយោបាយសុំដីអំពីក្រុងពាលី តែបីជំហាន។ ឯក្រុងពាលីពុំបានដឹងកលព្រះពុទ្ធបទុមុត្តរៈ នឹកក្នុងចិត្តថា «ដីបីជំហាននឹងអស់ប៉ុន្មាន ឲ្យទៅចុះ មិនជាការអ្វីទេ»។ គិតស្រេចហើយក៏ប្រាប់ទៅព្រះពុទ្ធបទុមុត្តរៈថា "ចូរអ្នកឈានឲ្យគ្រប់បីជំហាន យកចុះ"។ ឯព្រះពុទ្ធ

---

[៣] ដើម្បីអត្ថបទលម្អិតពីស្តេចស្វាពាលី សូមអានអត្ថបទ *«កេតនភណ្ឌរបស់ពាលី»* ក្នុងបណ្តាញព័ត៌មានអប្សរា (AMS) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១។

[៤] បណ្តាញព័ត៌មានអប្សរា (AMS) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

បទុមុត្តរៈ ក៏និម្មិតខ្លួនយ៉ាងធំ ហើយឈានតែមួយជំហានប៉ុណ្ណោះ ក៏ស្រាប់តែអស់ដីតែម្ដង។ ព្រះពុទ្ធបទុមុត្តរៈ ក៏បណ្ដេញក្រុងពាលី ឲ្យទៅនៅឯក្រៅចក្រវាឡ។ តែមុននឹងថយចេញទៅ ពាលីធ្វើសំណូមពរដល់ព្រះអង្គថា "ខ្ញុំព្រះអង្គសុខចិត្តថ្វាយទឹកដីចំពោះព្រះអង្គទាំងអស់ មិនមានតវ៉ាអ្វីឡើយ តែខ្ញុំព្រះអង្គសុំតែប៉ុណ្ណោះ ដើម្បីជាទីរឭកដល់ខ្ញុំព្រះអង្គដែលជាម្ចាស់ដើមនៃទឹកដីនេះ ជនណាដែលត្រូវការសង់គេហដ្ឋានក្ដី សង់អ្វីៗក្ដី សូមឲ្យធ្វើកិច្ចបូជានឹកដល់ខ្ញុំព្រះអង្គផង"។ ព្រះពុទ្ធបទុមុត្តរៈ ក៏សុខចិត្តប្រទានសំណូមពរនោះតាមបំណងក្រុងពាលី។[៥]

ប្រកពមួយទៀតតំណាលថា ក្នុងលទ្ធិព្រហ្មញ្ញសាសនា ក្រុងពាលីជាអ្នកមានឥទ្ធិឫទ្ធិម្នាក់ ដែលជាអ្នកគ្រប់គ្រងលោក អ្នកស្រុកអ្នកនគរ តែងគោរពកោតខ្លាចបេស្ដាបារមីនៃក្រុងពាលីនេះ តែព្រះឥសូរនិងព្រះនារាយណ៍ ដែលជាបងប្អូនបង្កើតនឹងគ្នា ជាអ្នកមានឫទ្ធានុភាពដ៏លើសលប់ដែរនោះ មានចិត្តចង់បានមនុស្សមកនៅក្រោមអំណាចរបស់ខ្លួន។ បើតាមរឿងនេះ ក្រុងពាលីមិនមែនជានាគទេ តែជាអាទិទេពមួយអង្គទៅវិញ។ គិតដូច្នេះហើយ ព្រះឥសូរក៏ប្រើព្រះនារាយណ៍ជាប្អូន ឲ្យទៅសុំដីបីជំហានពីក្រុងពាលី។ ព្រះនារាយណ៍កាឡាខ្លួនជាមនុស្សតឿម្នាក់ ទៅសុំដីបីជំហានពីក្រុងពាលី។ លុះក្រុងពាលីសម្រេចថាឲ្យហើយ ព្រះនារាយណ៍ក៏បញ្ចេញឥទ្ធិឫទ្ធិឈានយកដី ឈានមួយជំហានទៅដាន់ព្រហ្មលោក មួយជំហានទៀត ទៅជាន់ឋានបាតាល ឈានម្ដងទៀតជាគម្រប់ទី៣ ទៅជាន់ចំក្បាលក្រុងពាលី លិចបាត់ទៅក្នុងដីតែម្ដង។ ក្រុងពាលីក៏អង្វរសុំចុះចាញ់ ហើយថ្វាយទឹក-ដីទាំងអម្បាលម៉ាន ចំពោះព្រះនារាយណ៍ទាំងអស់ គ្រាន់តែសុំពរ ដូចនៅក្នុងរឿងទី១ដែរ។[៦]
ពិធីសែនក្រុងពាលីដើម្បីសង់រោងរៀននេះ ក៏ដូចគ្នានឹងរបៀបសែនក្រុងពាលីលើកផ្ទះថ្មីដែរ ដែលមានពិធីសែនក្រុងពាលីនិងព្រះភូមិមកដល់សព្វថ្ងៃ។ ពិធីប្រុងពលីនេះ មានការដឹកនាំធ្វើខុសប្លែកគ្នាតិចតួច ទៅតាមការនិយមរបស់អ្នកស្រុកតាមតំបន់នីមួយៗ។ ពិធីក្រុងពាលីនេះ ជាពិធីដែលខ្មែរបុរាណបានប្រារព្ធធ្វើតាំងពីបុរាណកាល រហូតមកដល់បច្ចុប្បន្ន។ ដោយអាស្រ័យជំនឿយ៉ាងមុតមាំ ទៅលើស្ដេចក្រុងពាលីដែលគេយល់ថាជា

[៥] ពេជ សល់ ១៩៧០: ៥៣-៥៤

[៦] ពេជ សល់ ១៩៧០: ៥៤

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

*ម្ចាស់ទឹកម្ចាស់ដី ទើបបានលោកអាចារ្យជំនាន់ក្រោយៗ យកចិត្តទុកដាក់ថែរក្សាទំនៀមទម្លាប់នេះ គង់វង្សរហូតមក៕*

**ឯកសារពិគ្រោះ**

ពេជ សល់. (១៩៧០). *អំពីលំនាំសង្ខេបនៃភ្លេងខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

Narayan, R. K. (1972). *The Ramayana*. New York: Penguin Books.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

*អត្ថបទដោយ៖ បណ្ឌិត សំ សំអាង*